ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# ឧបសម្ព័ន្ធ

## នៃរបាយការណ៍ប្រចាំឆ្នាំ២០២១

## របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍អភិបាលកិច្ចសាជីវកម្ម

## ប្រចាំឆ្នាំ២០២១

# ផ្នែកទី១. ភាគហ៊ុនិក

## ក. រចនាសម្ព័ន្ធភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១)

### ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១.៧៤១ | ៤.០២៥.២៩៦ | ៤,៦៩% |
| | | នីតិបុគ្គល | ៦ | ៣.៣០៥.១០៦ | ៣,៨៥% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣៦៨ | ៥១៩,៧៩២ | ០,៦១% |
| | | នីតិបុគ្គល | ៤ | ១៣.៥៩២.៧៩៨ | ២,៨៥% |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១១.១៥០.៣២៤ | ១៣,០០% |
| ចាប់ពី៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៦៤.៣២៨.៩៧៥ | ៧៥,០០% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

### ២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិករបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៦ | ២៨៨.៧៤៤ | ១៣,៤៧% |
| បុគ្គលិកជាន់ខ្ពស់ | ១៥ | ៣២០.៣៣៦ | ១៤,៩៤% |
| និយោជិត | ១៩៨ | ១.៥៣៥.២១៩ | ៧១,៦០% |
| **សរុប** | **២១៩** | **២.១៤៤.២៩៩** | **១០០,០០%** |

## ខ. សិទ្ធរបស់ភាគហ៊ុនិក និងការការពារសិទ្ធរបស់ភាគហ៊ុនិក

### ១. សិទ្ធរបស់ភាគហ៊ុនិក

ភាគហ៊ុនិករបស់ **កសស** មានសិទ្ធិដូចខាងក្រោម ៖

❖ **ភាគហ៊ុនិកប្រភេទ "ក"**

- **សិទ្ធិបោះឆ្នោត** ៖ ជាទូទៅភាគហ៊ុនិកប្រភេទ "ក" មិនមានសិទ្ធិបោះឆ្នោតឡើយ លើកលែងតែក្នុងករណីដែលមានកិច្ចប្រជុំសម្រេចលើបញ្ហាណាមួយ ដែលអាចប៉ះពាល់សិទ្ធិនិងផលប្រយោជន៍ នៃភាគហ៊ុនិកប្រភេទ "ក" ក្នុងនោះមានជាអាទិ៍ដូច ករណីខាងក្រោម ៖

- ការកាត់បន្ថយចំនួន ឬ ការរិតត្បិតសិទ្ធិនៃភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក"
- ការស្នើរួមបញ្ចូល ឬ ការបំបែក **កសស**
- ការសម្រេចឱ្យរំលាយ និងជម្រះបញ្ជី **កសស**

ក្នុងករណីនេះ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិបោះឆ្នោតដោយ ១ (មួយ) ភាគហ៊ុន ស្មើនឹង ១ (មួយ) សំឡេង ។

- **សិទ្ធិទទួលបានព័ត៌មាន ៖** ភាគហ៊ុនិកប្រភេទ "ក" មានសិទ្ធិទទួលបានព័ត៌មាន ដែលទាក់ទងនឹង **កសស** ស្របតាមច្បាប់ជាធរមាន ។
- **សិទ្ធិទទួលបានទ្រព្យ ដែលនៅសល់ពីការរំលាយ និងការជម្រះបញ្ជី** ៖ ភាគហ៊ុនិកដែលកាន់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិបុរិមាក្នុងការទទួលទ្រព្យសម្បត្តិរបស់ **កសស** ដែលនៅសល់បន្ទាប់ពីមានការរំលាយ និងការជម្រះបញ្ជី **កសស** មុនភាគហ៊ុនិកប្រភេទ "ខ" និង ប្រភេទ "គ" ដែលត្រូវបានកាន់កាប់គិតត្រឹមកាលបរិច្ឆេទនៃការរំលាយ និងការជម្រះបញ្ជី **កសស** ។

❖ **ភាគហ៊ុនិកប្រភេទ "ខ"**

- **សិទ្ធិបោះឆ្នោត** ៖ ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិបោះឆ្នោតពេញលេញដោយ ១ (មួយ) ភាគហ៊ុន ស្មើនឹង ១ (មួយ) សំឡេង ។
- **សិទ្ធិទទួលបានភាគលាភ** ៖ ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិទទួលបានភាគលាភនៅក្នុងឆ្នាំសារពើពន្ធណាមួយ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល **កសស** ។
- **សិទ្ធិទទួលបានព័ត៌មាន** ៖ ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិទទួលបានព័ត៌មានរបស់ **កសស** ស្របតាមច្បាប់ជាធរមាន ។
- **សិទ្ធិទទួលបានទ្រព្យដែលនៅសល់ពីការរំលាយ និងការជម្រះបញ្ជី** ៖ ភាគហ៊ុនិកប្រភេទ "ខ" ត្រូវទទួលទ្រព្យសម្បត្តិរបស់ **កសស** ដែលនៅសល់បន្ទាប់ពីមានការរំលាយ និងការជម្រះបញ្ជី **កសស** ប៉ុន្តែត្រូវគោរពតាមសិទ្ធិបុរិមាដែលបានផ្ដល់ជូនភាគហ៊ុនិកប្រភេទ "ក" ។
- **សិទ្ធិបរិវត្តន៍** ៖ ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិបរិវត្តន៍ក្នុងការបំលែងភាគហ៊ុនរបស់ខ្លួនទៅជាភាគហ៊ុនប្រភេទ "គ" តាមសមាមាត្រមួយភាគហ៊ុនប្រភេទ "ខ" ទៅជាមួយភាគហ៊ុនប្រភេទ "គ" ដោយត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម ៖
  - បន្ទាប់ពីផុតរយៈពេល ៣ (បី) ឆ្នាំ នៃការប្រកាស និងការធានាភាគលាភអប្បបរមាចំពោះភាគហ៊ុនប្រភេទ "គ" ។
  - **កសស** មិនមានភាគលាភអប្បបរមាត្រូវបានធានា ដែលមិនទាន់បានបែងចែករួច ។
  - ការធ្វើបរិវត្តន៍នៃភាគហ៊ុនប្រភេទ "ខ" នឹងមានអានុភាពនៅពេលមានការសម្រេចពីក្រុមប្រឹក្សាភិបាល **កសស** និងការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

❖ **ភាគហ៊ុនិកប្រភេទ "គ"**

- **សិទ្ធិបោះឆ្នោត** ៖ ភាគហ៊ុនិកប្រភេទ "គ" មានសិទ្ធិបោះឆ្នោតពេញលេញដោយ ១ (មួយ) ភាគហ៊ុន ស្មើនឹង ១ (មួយ) សំឡេង។

- **សិទ្ធិទទួលភាគលាភ ៖**
    - ភាគលាភដែលបែងចែកក្នុងចំណោមភាគហ៊ុនិកប្រភេទ "គ" ត្រូវបានប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ **កសស** ក្នុងឆ្នាំសារពើពន្ធ និងត្រូវអនុម័តដោយមហាសន្និបាតភាគហ៊ុនិក ។
    - ការបែងចែកភាគលាភ អាចជាសាច់ប្រាក់ ឬ ជាភាគហ៊ុន ទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល **កសស** និងទទួលការអនុម័តពីមហាសន្និបាតភាគហ៊ុនិក ហើយនឹងផ្តល់ជូនភាគហ៊ុនិក ដែលបានកាន់កាប់ភាគហ៊ុនមុនថ្ងៃអិចឌីវីឌិនដ៍ (Ex-Dividend Day) ។
- **សិទ្ធិទទួលព័ត៌មាន** ៖ ភាគហ៊ុនិកប្រភេទ "គ" មានសិទ្ធិទទួលបានព័ត៌មានរបស់ **កសស** ស្របតាមច្បាប់ជាធរមាន។
- **សិទ្ធិទទួលបានទ្រព្យដែលនៅសល់ពីការរំលាយ និងការជម្រះបញ្ជី** ៖ ភាគហ៊ុនិកប្រភេទ "គ" ត្រូវទទួលទ្រព្យសម្បត្តិរបស់ **កសស** ដែលនៅសល់បន្ទាប់ពីមានការរំលាយ និងការជម្រះបញ្ជី **កសស** ប៉ុន្តែត្រូវគោរពតាមសិទ្ធិបុរិមាដែលបានផ្តល់ជូនភាគហ៊ុនិកប្រភេទ "ក" និង ប្រភេទ "ខ" ។

## ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត

សិទ្ធិរបស់ភាគហ៊ុនិក ត្រូវបានធានាដោយមហាសន្និបាតភាគហ៊ុនិក ដោយក្រុមប្រឹក្សាភិបាល និងដោយអគ្គនាយកដូចដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់ **កសស** ហើយភាគហ៊ុនិកមានសិទ្ធិទទួលព័ត៌មានស្មើៗគ្នា ក្នុងពេលតែមួយមិនថាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនតិច ឬច្រើន ។ គ្រប់ភាគហ៊ុនិករបស់ **កសស** ទាំងអស់ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ និងមានសិទ្ធិក្នុងការសួរទៅលើ លទ្ធផលប្រតិបត្តិការណ៍ ការអនុវត្តន៍និងផែនការអភិវឌ្ឍន៍នានារបស់កំពង់ផែ ។ លើសពីនេះ សមាជិកក្រុមប្រឹក្សាភិបាលក៏មានអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ដើម្បីការពារផលប្រយោជន៍ដល់ភាគហ៊ុនិកទាំងអស់ ។

## ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្ត

សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនតិច ក៏ត្រូវបានធានាដោយមហាសន្និបាតភាគហ៊ុនិក ដោយក្រុមប្រឹក្សាភិបាល និងដោយអគ្គនាយកដូចដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់ **កសស** ហើយភាគហ៊ុនិកទាំងនោះមានសិទ្ធិទទួលបានព័ត៌មានស្មើៗគ្នា និងក្នុងពេលតែមួយមិនថាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនតិច ឬច្រើន។ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច ក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ និងមានសិទ្ធិក្នុងការសួរទៅលើ លទ្ធផល ប្រតិបត្តិការណ៍ ការអនុវត្តន៍និងផែនការអភិវឌ្ឍន៍នានារបស់កំពង់ផែ ។

## គ. មហាសន្និបាតភាគហ៊ុនិក

### ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

<u>នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក</u>

- មហាសន្និបាតភាគហ៊ុនិកត្រូវធ្វើឡើង ០១ (មួយ) ឆ្នាំម្តង បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធស្របតាមកាលបរិច្ឆេទ និងរបៀបវារៈដែលត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល។
- មហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ អាចប្រព្រឹត្តទៅបានក្នុងករណីមានសេចក្តីស្នើសុំដោយភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនយ៉ាងតិចចំនួន ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនប្រភេទ "ខ" និងប្រភេទ "គ" ។
- សេចក្តីស្នើសុំកោះប្រជុំរបស់ភាគហ៊ុនិក ត្រូវផ្ញើជូនក្រុមប្រឹក្សាភិបាលយ៉ាងតិច ២១ (ម្ភៃមួយ) ថ្ងៃមុនថ្ងៃប្រជុំ ដោយមានចុះហត្ថលេខា និងភ្ជាប់របៀបវារៈជាមួយផង។
- ប្រសិនបើមហាសន្និបាតភាគហ៊ុនិក ពុំអាចប្រព្រឹត្តិទៅបានតាមនីតិវិធីដូចចែងខាងលើ នោះសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកណាម្នាក់ដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក អាចស្នើសុំតុលាការឱ្យចាត់ចែងកោះប្រជុំមហាសន្និបាតភាគហ៊ុនិក តាមនីតិវិធីណាមួយដែលតុលាការពិចារណាឃើញថាសមស្រប។
- មហាសន្និបាតភាគហ៊ុនិក ប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយក។ ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយកអវត្តមាន នោះសមាជិកក្រុមប្រឹក្សាភិបាលដែលជាអាណត្តិគាហកៈតំណាងអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើជាអធិបតី។
- ប្រធានមហាសន្និបាតភាគហ៊ុនិក មានសិទ្ធិបោះឆ្នោតលុះត្រាតែបានទទួលការផ្ទេរសិទ្ធិពីភាគហ៊ុនិកណាម្នាក់ ឬខ្លួនជាភាគហ៊ុនិក។
- មហាសន្និបាតភាគហ៊ុនិក ត្រូវប្រព្រឹត្តទៅនៅទីស្នាក់ការចុះបញ្ជីរបស់ **កសស** ឬនៅទីកន្លែងផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានកំណត់ដោយប្រធានក្រុមប្រឹក្សាភិបាល។
- សេចក្តីជូនដំណឹងពីមហាសន្និបាតភាគហ៊ុនិក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវផ្ញើទៅភាគហ៊ុនិកតាមរយៈលិខិត ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬតាមគ្រប់មធ្យោបាយសមស្របណាមួយ ដោយមានបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបវារៈ។
- សេចក្តីជូនដំណឹងត្រូវផ្ញើទៅភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោត ទៅអភិបាលរបស់ **កសស** មិនលើសពី ២១ (ម្ភៃមួយ) ថ្ងៃ មុនកាលបរិច្ឆេទរបស់មហាសន្និបាតភាគហ៊ុនិក ។

<u>នីតិវិធីនៃការរៀបចំការបោះឆ្នោត</u>

ដំណើរការនៃការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ក្នុងមហាសន្និបាតភាគហ៊ុនិករបស់ **កសស** ត្រូវកំណត់ដូចខាងក្រោម ៖

## ការចុះវត្តមានអង្គបោះឆ្នោត និងកូរ៉ុម

- ការចុះវត្តមាន ធ្វើនៅពេលមហាសន្និបាតភាគហ៊ុនិក ដោយភ្ជាប់មកជាមួយនូវលិខិតអញ្ជើញ ឬលេខអត្តសញ្ញាណវិនិយោគិន។ ក្នុងករណីមានការផ្ទេរសិទ្ធិបោះឆ្នោត នោះអ្នកទទួលសិទ្ធិត្រូវភ្ជាប់មកជា មួយនូវលិខិតផ្ទេរសិទ្ធិ និងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ។
- អង្គបោះឆ្នោត គឺជាភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ (កាលបរិច្ឆេទកំណត់ទុក)។
- ការបោះឆ្នោតអាចប្រព្រឹត្តទៅបាន លុះត្រាមានកូរ៉ុមវត្តមានភាគហ៊ុនិក តំណាងអោយចំនួនភាគហ៊ុនលើសពីពាក់កណ្តាលនៃភាគហ៊ុនសរុប។

## ការប្រគល់សិទ្ធិ

- ភាគហ៊ុនិក អាចប្រគល់សិទ្ធិអោយអ្នកតំណាងរបស់ខ្លួនចូលរួមបោះឆ្នោតជំនួសបាន។ ភាគហ៊ុនិកដែលប្រគល់សិទ្ធិអោយគេបោះឆ្នោតជំនួស មិនមានសិទ្ធិក្នុងការបោះឆ្នោតទៀតទេ។
- អ្នកទទួលសិទ្ធិ ពុំចាំបាច់ជាម្ចាស់ភាគហ៊ុនទេ។
- អ្នកទទួលសិទ្ធិ អាចទទួលបានការប្រគល់សិទ្ធិ ពីភាគហ៊ុនិកតែម្នាក់ប៉ុណ្ណោះ។
- លិខិតប្រគល់សិទ្ធិត្រូវផ្តល់ជូនមកគណៈកម្មការរៀបចំការបោះឆ្នោត អោយបានមុនពេលដំណើរការបោះឆ្នោត។ ការប្រគល់សិទ្ធិ ត្រូវប្រកាសជាសាធារណៈក្នុងមហាសន្និបាតភាគហ៊ុនិក។
- លិខិតប្រគល់សិទ្ធិ ត្រូវភ្ជាប់ជូនមកជាមួយនូវលិខិតអញ្ជើញ ។
- លិខិតប្រគល់សិទ្ធិ ត្រូវមានហត្ថលេខារបស់ភាគហ៊ុនិកប្រគល់សិទ្ធិ និងអ្នកទទួលសិទ្ធិ។

## ការឃោសនាបោះឆ្នោត

- ការឃោសនាបោះឆ្នោតមានរយៈពេល ១០នាទី សម្រាប់បេក្ខជនដើម្បីបង្ហាញ និងណែនាំពីសមត្ថភាព បទពិសោធន៍ការងារ និងទិសដៅការងារ ។
- ការឃោសនា ត្រូវធ្វើឡើងនៅក្នុងមហាសន្និបាតក្រោមរូបភាពដោយផ្ទាល់មាត់ ឬ/និង ដោយបទបង្ហាញជាស្លាយ (Power Point Slide) ។
- គ្រប់រូបភាព និងសកម្មភាពឃោសនា មិនត្រូវមានការវាយប្រហាររិះគន់លើបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ឬសកម្មភាពការងាររបស់បេក្ខជនដទៃទៀយ។ ក្នុងករណីមានការបំពាន គណៈកម្មការរៀបចំការបោះឆ្នោតមានសិទ្ធិបញ្ឈប់ការឃោសនារបស់បេក្ខជននោះភ្លាមៗ ។

## ការិយាល័យបោះឆ្នោត និងបន្ទប់សម្ងាត់

- ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការរៀបចំការបោះឆ្នោត។
- ការិយាល័យបោះឆ្នោត ត្រូវរៀបចំក្នុងសាលមហាសន្និបាត។ ការិយាល័យបោះឆ្នោតត្រូវមានបន្ទប់សម្ងាត់តាមការចាំបាច់សម្រាប់ភាគហ៊ុនិកចូលទៅបោះឆ្នោត។
- ការិយាល័យបោះឆ្នោត ត្រូវមានសមាជិកគណៈកម្មការយ៉ាងតិច ០៥ រូប រួមមានប្រធាន ០១ រូប និងសមាជិកយ៉ាងតិចចំនួន ០៤ រូប ។

- ប្រធានការិយាល័យបោះឆ្នោតទទួលពិនិត្យការងាររួម និងប្រកាសហៅឈ្មោះអ្នកបោះឆ្នោតតាមបញ្ជីចុះវត្តមាន។ សមាជិក ០២ រូប ទទួលបន្ទុកសណ្តាប់ធ្នាប់ខាងក្រៅការិយាល័យ និងចំនួន ០២ រូបទៀត ទទួលបន្ទុកសណ្តាប់ធ្នាប់ខាងក្នុងការិយាល័យ ។

## របៀបនៃការបោះឆ្នោត

- របៀបនៃការបោះឆ្នោត ត្រូវធ្វើឡើងដោយការហៅឈ្មោះភាគហ៊ុនិក ដែលបានចុះបញ្ជីវត្តមានដោយក្នុងមួយលើកមានចំនួន ១០ រូប ។
- ប្រធានមហាសន្និបាត សមាជិកក្រុមប្រឹក្សាភិបាល បេក្ខជនឈរឈ្មោះ និងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតទាំងអស់ ត្រូវបានអនុញ្ញាតអោយឡើងធ្វើការបោះឆ្នោតមុន។
- ភាគហ៊ុនិក ដែលអវត្តមានពេលប្រកាសហៅឈ្មោះ ត្រូវផ្តល់ឱកាសអោយឡើងបោះឆ្នោតបាននៅពេលភាគហ៊ុនិករូបនោះមានវត្តមានពេលកំពុងបោះឆ្នោត និងមុនពេលប្រកាសបិទការិយា ល័យបោះឆ្នោតជាផ្លូវការ។
- ភាគហ៊ុនិកដែលត្រូវបានហៅឈ្មោះអោយឡើងទៅបោះឆ្នោត ត្រូវចូលទៅបន្ទប់សម្ងាត់បោះឆ្នោតដើម្បីទម្លាក់បណ្ណបោះឆ្នោតគាំទ្របេក្ខជនឈរឈ្មោះដែលខ្លួនពេញចិត្តនៅក្នុងហិបឆ្នោត ដែលមានបិទឈ្មោះ និងរូបថតរបស់បេក្ខភាពជាអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។

## ការបោះឆ្នោត

- ការបោះឆ្នោតជ្រើសតាំងជាអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនត្រូវប្រព្រឹត្តទៅដោយសេរី ជាសម្ងាត់ និងតម្លាភាព។
- ការបោះឆ្នោតជ្រើសតាំង ធ្វើឡើងតាមប្រព័ន្ធជាឯកត្តនាម ។
- ការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យធ្វើឡើងដោយភាគហ៊ុនិកសាធារណៈ និងភាគហ៊ុនិកឯកជន។
- ការបោះឆ្នោតជ្រើសតាំង អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ធ្វើឡើងដោយភាគហ៊ុនិកឯកជន តែប៉ុណ្ណោះ ដោយពុំអនុញ្ញាតអោយភាគហ៊ុនិកសាធារណៈចូលរួមបោះឆ្នោតឡើយ។
- បេក្ខជនដែលបានឈរឈ្មោះហើយជាប់ឆ្នោត គឺជាបេក្ខជនដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេ ។
- ការបោះឆ្នោតជ្រើសតាំងជាអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនត្រូវធ្វើតែមួយលើក។
- គណៈកម្មការរៀបចំការបោះឆ្នោត មានសមត្ថកិច្ចដោះស្រាយបញ្ហានានាដែលកើតមាននៅពេលបោះឆ្នោត ឬនៅពេលរាប់សន្លឹកឆ្នោត។

## បណ្ណបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល

- បណ្ណបោះឆ្នោតមាន ២ប្រភេទ ៖
- ពណ៌ខៀវ សម្រាប់ការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ

- ពណ៌ក្រហម សម្រាប់ការបោះឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។
- បណ្ណបោះឆ្នោតនឹងត្រូវផ្តល់ជូននៅពេលដែលភាគហ៊ុនិក ឬអ្នកផ្ទេរសិទ្ធិចុះវត្តមាន។ បណ្ណបោះឆ្នោតមានបញ្ជាក់ពីលេខអត្តសញ្ញាណវិនិយោគិន និងចំនួនភាគហ៊ុនដែលភាគហ៊ុនិកកាន់កាប់ ។
- ភាគហ៊ុនិកត្រូវទម្លាក់បណ្ណបោះឆ្នោត ទៅក្នុងហិបឆ្នោតអោយបានត្រឹមត្រូវ តាមពណ៌នៃបណ្ណបោះឆ្នោត។ ការទម្លាក់បណ្ណបោះឆ្នោតខុសហិបឆ្នោត ឬគូសលើបណ្ណបោះឆ្នោត ឬសរសេរបន្ថែមដោយអ្នកបោះឆ្នោត ត្រូវចាត់ទុកជាបណ្ណបោះឆ្នោតឥតបានការ ។
- ភាគហ៊ុនិក អាចសុំជំនួយពីគណៈកម្មការរៀបចំការបោះឆ្នោត ដើម្បីណែនាំពីរបៀបបោះឆ្នោតអោយបានត្រឹមត្រូវ ។
- ការរាប់ និងការបូកសរុបលទ្ធផលបោះឆ្នោត ត្រូវធ្វើតាមប្រព័ន្ធព័ត៌មានវិទ្យា (កុំព្យូទ័រ) ។
- ប្រធានការិយាល័យបោះឆ្នោតត្រូវពិនិត្យ និងលើកបង្ហាញបណ្ណបោះឆ្នោត ហើយសមាជិក ០២រូបត្រូវកត់ត្រាតាមប្រព័ន្ធកុំព្យូទ័រ និង ០២ រូបទៀត ត្រូវរៀបបណ្ណបោះឆ្នោតតាមពំនូកនូវបណ្ណបោះឆ្នោតបានការ និងមិនបានការ ។
- លទ្ធផលនៃការបោះឆ្នោតត្រូវប្រកាសដោយប្រធានមហាសន្និបាតភាគហ៊ុនិក។

**ការប្តឹងតវ៉ាចំពោះលទ្ធផលបោះឆ្នោត**

- គណៈកម្មការរៀបចំការបោះឆ្នោត មានសមត្ថកិច្ចដោះស្រាយបញ្ហានានាដែលកើតមាននៅក្រោយពេលបោះឆ្នោត ។
- បេក្ខជនដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិប្តឹងតវ៉ាចំពោះលទ្ធផលបោះឆ្នោតបាននៅចំពោះមុខគណៈកម្មការរៀបចំការបោះឆ្នោត ។

## ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|---|
| ១ | ២៥-មិថុនា ២០២១ | សាមញ្ញ | ៧៩.០០៥.៣៥៥ ភាគហ៊ុន ស្មើនឹង ៩២,១១% នៃចំនួនភាគហ៊ុនសរុប | - របាយការណ៍លទ្ធផលអាជីវកម្ម-សេវាកម្ម ឆ្នាំ ២០២០<br>- របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣១ ធ្នូ ២០២០ (បានធ្វើសវនកម្ម)<br>- ទិសដៅការងារឆ្នាំ២០២១<br>- ការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ ២០២០ និងប្រាក់លាភ | -ការអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២០<br>-កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ (Record date) គឺនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១។<br>-ការអនុម័តលើប្រាក់ |

| | | | | ការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ សម្រាប់ឆ្នាំ២០២១<br>- ការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សំរាប់អាណត្តិទី៨<br>- ប្រកាសលទ្ធផលការបោះឆ្នោត | លាភការ សម្រាប់ក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ ឆ្នាំ២០២១<br>-អនុម័តជ្រើសតាំងលោក **ហ៊ុន មុន្នីវណ្ណ** ជាអភិបាលឯករាជ្យ<br>-និង លោក Hidetoshi KUME ជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន |
|---|---|---|---|---|---|

## ឃ. ការបែងចែកភាគលាភ

### ១. គោលនយោបាយបែងចែកភាគលាភ

ដើម្បីជាការលើកទឹកចិត្តដល់វិនិយោគិន ក្រុមប្រឹក្សាភិបាលបានអនុម័តគោលនយោបាយភាគលាភ ដែលមានការធានាទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំស្មើនឹងចំនួន ៥% នៃទំហំវិនិយោគ ដោយគិតតាមថ្លៃបោះផ្សាយលក់មូលបត្រ (IPO) សម្រាប់រយៈពេល ៣ឆ្នាំ បន្ទាប់ពីការចុះបញ្ជីលក់លើផ្សារមូលបត្រកម្ពុជា។ ការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹងចំនួន ៥% នេះ គឺនឹងផ្តល់ជូនចំពោះមូលបត្រកម្មសិទ្ធដែលមានសិទ្ធបោះឆ្នោតប្រភេទ "គ" តែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលកម្ពុជា ដែលជាភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធមានសិទ្ធបោះឆ្នោតប្រភេទ "ខ" និងមូលបត្រកម្មសិទ្ធគ្មានសិទ្ធបោះឆ្នោតប្រភេទ "ក" មិនទទួលបានការធានាភាគលាភទេ។

ក្រោយពីផុតការធានារយៈពេល ៣ឆ្នាំ រួចមក ការបែងចែកភាគលាភត្រូវបានស្នើរឡើងដោយក្រុមប្រឹក្សាភិបាល ហើយដាក់អោយមហាសន្និបាតភាគហ៊ុនិកធ្វើការសម្រេច។

### ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ២៥ មិថុនា ២០២១ | ៥ មិថុនា ២០២០ | ១២ មេសា ២០១៩ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ០៥ កក្កដា ២០២១ | ១០ មិថុនា ២០២០ | ០៣ ឧសភា ២០១៩ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ១៤ កក្កដា ២០២១ | ២២ មិថុនា ២០២០ | ១០ ឧសភា ២០១៩ |

## ផ្នែកទី២. ក្រុមប្រឹក្សាភិបាល

### ក. ក្រុមប្រឹក្សាភិបាល

### ១- សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯ.ឧ លូ គឹមឈន់ | ប្រធាន | ០៥ ឧសភា ២០២១ | ០៤ ឧសភា ២០២៤ |
| ២ | ឯ.ឧ ស៊ុយ សាន | សមជិក | ០៥ ឧសភា ២០២១ | ០៤ ឧសភា ២០២៤ |
| ៣ | ឯ.ឧ ផាន់ផល្លា | សមាជិក | ០៥ ឧសភា ២០២១ | ០៤ ឧសភា ២០២៤ |
| ៤ | ឯ.ឧ សុខ សុភ័ក្រ្ត | សមាជិក | ០៥ ឧសភា ២០២១ | ០៤ ឧសភា ២០២៤ |
| ៥ | លោក ហ៊ុន មុន្នីវណ្ណ | សមាជិក | ២៥ មិថុនា ២០២១ | ២៤ មិថុនា ២០២៤ |
| ៦ | លោក Hidetoshi KUME | សមាជិក | ២៥ មិថុនា ២០២១ | ២៤ មិថុនា ២០២៤ |
| ៧ | លោក លូ លីខេង | សមាជិក | ២១ មិថុនា ២០២១ | ២០ មិថុនា ២០២៤ |

# ២ - ជីវប្រវត្តិសង្ខេបរបស់អភិបាល



## ឯកឧត្តម លូ គឹមឈន់

### ប្រធានអគ្គនាយក

### ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ឯកឧត្តម កើតនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៥៦ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិព្រៃកពោធិ ឃុំព្រៃកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

- **ប្រវត្តិនៃការសិក្សា**

នៅឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញសំណង់ក្នុងទឹក និងកំពង់ផែ នៅប្រទេសរុស្ស៊ី។ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញពាណិជ្ជសាស្ត្រ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា។ ហើយពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ ឯកឧត្តមបានបញ្ចប់ថ្នាក់បណ្ឌិត លើជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា។

- **បទពិសោធន៍ការងារ**

ឯកឧត្តមបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅក្នុងអំឡុងឆ្នាំ ១៩៨៦ មានតួនាទីជាបុគ្គលិកវិស្វករសំណង់ នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈសំណង់។ ហើយនៅឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩២ ឯកឧត្តមមានតួនាទីជាអនុប្រធានកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងនៅឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៩ ឯកឧត្តមមានតួនាទីជាប្រធានកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ នៅក្នុងឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៨ ឯកឧត្តមទទួលបានតួនាទីជាប្រធានអគ្គនាយកកំពង់ផែក្រុងព្រះសីហនុ និងចាប់ពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ឯកឧត្តមជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។



# ឯកឧត្តម ស៊ុយ សាន
## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន

ឯកឧត្តម កើតនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៥៨ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិបំណក់ ឃុំឈើគុំ ស្រុកក្រគរ ខេត្តពោធិសាត់ ។

- **ប្រវត្តិនៃការសិក្សា**

  នៅឆ្នាំ១៩៩៤ ឯកឧត្តមបានបញ្ចប់ថ្នាក់បណ្ឌិត លើជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា។

- **បទពិសោធន៍ការងារ**

  ក្នុងអំឡុងឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨១ ឯកឧត្តមបានចូលបម្រើការងារនៅសាលាខេត្តពោធិសាត់ ដែលមានតួនាទីគ្រប់គ្រងរដ្ឋបាល ហើយនៅឆ្នាំ១៩៨១ ដល់ ឆ្នាំ១៩៩៤ ឯកឧត្តមមានតួនាទីជាអនុប្រធានគណកម្មធិការផែនការ ខេត្តពោធិសាត់។ នៅឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៨ ឯកឧត្តមមានតួនាទីជាជំនួយការ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ហើយនៅឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៣ ឯកឧត្តមទទួលបានតួនាទីជាអភិបាលរងខេត្តសៀមរាប។ ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៨ ឯកឧត្តមបានចូលបម្រើការងារនៅក្រសួងសាធារណការ និងដឹកជញ្ជូន មានតួនាទីជានាយកខុទ្ទកាល័យ។ នៅឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ឯកឧត្តមទទួលបានតួនាទីជាជំនួយការទេសរដ្ឋមន្ត្រី។ ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ ឯកឧត្តមមានតួនាទីជានាយកខុទ្ទកាល័យក្រសួងពាណិជ្ជកម្ម ហើយចាប់ពីឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន ឯកឧត្តមទទួលបានតួនាទីជាអនុរដ្ឋលេខាធិកា និងជានាយកខុទ្ទកាល័យក្រសួងសាធារណការ និងដឹកជញ្ជូន ។



# ឯកឧត្តម ផាន់ ផល្លា
## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឯកឧត្តម កើតនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៧៣ សញ្ជាតិ ខ្មែរ ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញរដ្ឋបាលពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ Hawaii Pacific សហរដ្ឋអាមេរិក។ ឆ្នាំ១៩៩៩ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ New South Wales ប្រទេសអូស្ត្រាលី ។ ហើយនៅឆ្នាំ២០០៣ ឯកឧត្តមបានបញ្ចប់ថ្នាក់បណ្ឌិត លើជំនាញសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ Wollonggong ប្រទេសអូស្ត្រាលី។

- **បទពិសោធន៍ការងារ**

ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ឯកឧត្តមមានតួនាទីជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ ឯកឧត្តមមានតួនាទីជាអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចាប់ពីឆ្នាំ២០១៦ ដល់បច្ចុប្បន្ន ឯកឧត្តមទទួលបានតួនាទីជាអនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។



# ឯកឧត្តម សុខ សុភ័ក្រ្ត
## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងពាណិជ្ជកម្ម

ឯកឧត្តម កើតនៅថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៥៨ សញ្ជាតិ ខ្មែរ ។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨៦ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្ររង លើជំនាញបច្ចេកទេសអគ្គិសនី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩២ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញសេដ្ឋកិច្ច នៅវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩៧ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ London ប្រទេសអង់គ្លេស ហើយនៅឆ្នាំ២០០០ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគោលនយោបាយសាធារណៈ នៅសាកលវិទ្យាល័យ Saitama ប្រទេសជប៉ុន ។

➢ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨២ ឯកឧត្តមបានចូលបម្រើការងារនៅអាជ្ញាធរអគ្គិសនីខេត្តកោះកុង ទទួលបន្ទុកជាប្រធានអាជ្ញាធរអគ្គិសនីខេត្ត។ នៅចុងឆ្នាំ១៩៩២ ឯកឧត្តមបានផ្លាស់មកបម្រើការងារនៅក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកជាសមាជិកក្រុមជំនួយការ នៃរដ្ឋមន្ត្រី។ នៅក្នុងឆ្នាំ១៩៩៩ ឯកឧត្តមត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ហើយមានតួនាទីយ៉ាងសំខាន់ក្នុងនាមជាសមាជិកក្រុមអ្នកចរចាពាណិជ្ជកម្ម សម្រាប់ការធ្វើសមាហរណកម្មកម្ពុជានៅក្នុងក្របខ័ណ្ឌអាស៊ាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានបូកមួយ និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ ឯកឧត្តមមានតួនាទីជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងពាណិជ្ជកម្ម។ ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤ ឯកឧត្តមទទួនបានតួនាទីជាអគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម។ នៅឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ ឯកឧត្តមមានតួនាទីជាអគ្គនាយក នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម និងពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧ ឯកឧត្តមទទួលបានតួនាទីជាអនុរដ្ឋលេខធិការក្រសួងពាណិជ្ជកម្ម ចាប់ពីឆ្នាំ២០១៨ មកដល់បន្ទុប្បន្ន ឯកឧត្តមទទួលបានតួនាទីជារដ្ឋលេខធិការក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកលើប្រតិបត្តិការ និងការកែទំរង់របស់អគ្គនាយកដ្ឋានគាំទ្រសេវាពាណិជ្ជកម្មកម្ម និងគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ ។



# លោក ហ៊ុន មុន្នីវណ្ណ
## អភិបាលឯករាជ្យ

លោក ហ៊ុន មុន្នីវណ្ណ កើតនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៣ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

- **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៧ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រង លើជំនាញគណនេយ្យនៅសាកលវិទ្យាល័យ វេទមហាឥសី ប្រទេសកម្ពុជា។ ពីឆ្នាំ២០១៧ ដល់បច្ចុប្បន្ន លោកកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងអាជីវកម្មតាមអនឡាញ នៅសាកលវិទ្យាល័យក្រុងឡុងដ៍ ចក្រភពអង់គ្លេស ។

- **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩២ លោកបានចូលបម្រើការងារនៅអង្គភាពនយោបាយ T88 កងប្រដាប់អាវុធនៃកម្ពុជា មានតួនាទីជាជំនួយការប្រធានអង្គភាព។ ឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០០ លោកជា សវនករជាន់ខ្ពស់នៃ Ernst & Young រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ នៅឆ្នាំ២០០០ ដល់ឆ្នាំ២០០៨ លោកជាប្រធានហិរញ្ញវត្ថុនៃសិប្បកររអង្គរ ខូ.,អិលធីឌី., ហើយក្នុងឆ្នាំ២០០៣ លោកទទួលបានតួនាទីជាក្រុមប្រឹក្សាភិបាលសិប្បកររអង្គរ ខូ.,អិលធីឌី., តំណាងឱ្យបុគ្គលិក។ នៅក្នុងឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ លោកជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្មនៃស្ពាបនា លីមីតធីត ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ លោកមានតួនាទីជាប្រធានក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មនៃស្ពាបនា លីមីតធីត។ នៅខែសីហា ឆ្នាំ២០០៨ ដល់ខែធ្នូ ឆ្នាំ២០១១ លោកមានតួនាទីជាប្រធានចាត់ការទូទៅនៃកសិកររីករាយ ខូ.,អិលធីឌី.,។ ហើយនៅឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ លោកជាក្រុមប្រឹក្សាភិបាលនៃសមាគមសហគ្រិនវ័យក្មេងនៅកម្ពុជា (YEAC)។ ខែមិថុនា ឆ្នាំ២០១១ ដល់បច្ចុប្បន្ន លោកជាអនុប្រធានសភាពាណិជ្ជកម្ម ខេត្តសៀមរាប និងឧត្តមានជ័យ (SROCC)។ នៅឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ លោកជាប្រធានសមាគមអតីតនិស្សិត IATSS កម្ពុជា (CIAA)។ ពីឆ្នាំ២០១៣ ដល់បច្ចុប្បន្ន លោកជាអនុប្រធាន និងក្រុមប្រឹក្សានៃក្លឹបវិនិយោគិនកម្ពុជា (CIC Investment Plc.) ហើយលោកក៏ជាប្រធានក្រុមប្រឹក្សាភិបាលនៃមេហ្គា លីស៊ីង ភីអិលស៊ី ផងដែរ។ រហូតដល់ឆ្នាំ២០១៤ លោកមានតួនាទីជានាយកប្រតិបត្តិ នៃអចលនទ្រព្យសកម្មប្រទេសកម្ពុជា ខូ.,អិលធីឌី។ នៅឆ្នាំ២០១៦ លោកជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្មនៃធនាគាស្ពាបនា ភីអិលស៊ី ហើយពីឆ្នាំ២០១៧ ដល់បច្ចុប្បន្ន លោកជាមាជិកវិទ្យាស្ថានអូស្ត្រាលី នៃនាយកក្រុមហ៊ុន (AICD) និងជាប្រធានគណៈកម្មការសវនកម្ម កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។



# លោក Hidetoshi KUME
# អភិបាលមិនប្រតិបត្តិ
# តំណាងភាគហ៊ុនិកឯកជន

លោក Hidetoshi KUME កើតនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ សញ្ជាតិ ជប៉ុន ។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៨០ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យ Kyusgshu លើជំនាញវិស្វករប្រត្តិកម្មប្រព័ន្ធទឹកកខ្វក់។ នាឆ្នាំ១៩៨២ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ Kyusgshu លើជំនាញវិស្វករប្រត្តិកម្មប្រព័ន្ធទឹកកខ្វក់ ប្រទេសជប៉ុន ។

➢ **បទពិសោធន៍ការងារ**

ក្នុងអំឡុងឆ្នាំ១៩៨២ លោកបានចូលបម្រើការងារជាមន្ត្រីបច្ចេកទេស ផ្នែកអភិវឌ្ឍន៍កំពង់ផែ និងសមុទ្រនៅក្រសួងដឹកជញ្ជូន។ ចាប់ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩០ លោកជាមន្ត្រីភ្នាក់ងារដែនដី ទទួលបន្ទុកខាងគម្រោង, ផ្នែកអភិវឌ្ឍន៍តំបន់រាជធានី (តំបន់ Kansai) និងឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩២ លោកមានតួនាទីជាប្រធានផ្នែកគម្រោងនៅវិទ្យាស្ថានស្រាវជ្រាវ ផ្នែកកំពង់ផែ និងសមុទ្រនៃក្រសួងដឹកជញ្ជូន ទទួលបន្ទុករួមក្នុងកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយសិក្ខាកាមមកពីក្រៅប្រទេស ដែលកាន់ផ្នែកកំពង់ផែ និងអាកាសយានដ្ឋាន។ នៅឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៦ លោកមានតួនាទីជាលេខាទីមួយ នៃនាយកដ្ឋានសេដ្ឋកិច្ចរបស់ស្ថានទូតជប៉ុន ប្រចាំប្រទេសភីលីពីន ទទួលបន្ទុកជាជំនួយការផ្នែកសេដ្ឋកិច្ចនៃរដ្ឋាភិបាលជប៉ុន នៅក្នុងប្រទេសភីលីពីន។ ឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៨ លោកមានតួនាទីជាប្រធានការិយាល័យកំពង់ផែ Takamatsu និងការសាងសង់អាកាសយានដ្ឋាននៃការិយាល័យសាងសង់កំពង់ផែទី៣ និងឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០១ លោកជាប្រធានការិយាល័យសាងសង់កំពង់ផែទី២ ក្នុងស្រុក នៅក្រសួងដឹកជញ្ជូន។ នៅឆ្នាំ១៩៩៧ ដល់ ឆ្នាំ១៩៩៩ លោកជាអ្នកស្រាវជ្រាវជាន់ខ្ពស់ការិយាល័យគម្រោងនៅវិទ្យាស្ថានអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រ ទទួលបន្ទុកលើការសិក្សាពីយុទ្ធសាស្ត្រការអភិវឌ្ឍន៍កំពង់ផែ ដែលជាគោលនយោបាយទី១ របស់គម្រោង JICA ក្នុងការអភិវឌ្ឍន៍តំបន់កំពង់ផែ។ ពីឆ្នាំឆ្នាំ២០០២ ដល់ឆ្នាំ២០០៤ លោកជាអភិបាលខេត្ត Okinawa មានតួនាទីជាទីប្រឹក្សាផ្នែកសាងសង់។ ឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ លោកមានតួនាទីជានាយករង នៃនាយកដ្ឋានកំពង់ផែ និងសមុទ្រនៅក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន ទទួលបន្ទុកផ្នែកផ្សព្វផ្សាយ និងការពារគ្រោះមហន្តរាយឯកជន។ នៅឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៧ លោកមានតួនាទីជាអភិបាលក្រុង Fukuoka និងជាទីប្រឹក្សានាយកដ្ឋានកំពង់ផែ និងសមុទ្រផងដែរ។ ឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ លោកមានតួនាទីជាអ្នកស្រាវជ្រាវជាន់ខ្ពស់ គម្រោងស្រាវជ្រាវអន្តរជាតិ "ការផ្លាស់ប្តូរអាកាសធាតុ និងយុទ្ធសាស្ត្រដឹកជញ្ជូនតាមផ្លូវអាកាស" នៅវិទ្យាស្ថានការសិក្សាគោលនយោបាយដឹកជញ្ជូន។ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០ លោកមានតួនាទីជានាយករង នៃក្រសួងដែនដីហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២ លោកមានតួនាទីជានាយកនៃនាយកដ្ឋានសិក្សា

ស្រាវជ្រាវ នៅវិទ្យាស្ថានការសិក្សាគោលនយោបាយដឹកជញ្ជូន។ ហើយនៅឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ លោកជានាយកនៅមជ្ឈមណ្ឌលកែលម្អបរិស្ថានតំបន់ឆ្នេរ Osa Bay។ ខែឧសភា ឆ្នាំ២០១៤ ដល់ ខែមីនា ឆ្នាំ២០១៨ អ្នកជំនាញការនៅក្រសួងសាធារណការនិងដឹកជញ្ជូន នៃប្រទេសកម្ពុជា មានតួនាទីជាទីប្រឹក្សាគោលការណ៍ផ្នែកដឹកជញ្ជូន និងចាប់ពីខែមិថុនា ឆ្នាំ២០១៨ លោកមានតួនាទីជានាយកនៃនាយកដ្ឋានដឹកជញ្ជូនតាមផ្លូវសមុទ្រ។



# លោក លូ លីខេង
# សមាជិកក្រុមប្រឹក្សាភិបាល
# តំណាងនិយោជិត កសស

លោក លូ លីខេង កើតថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៤ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

➢ **ប្រវត្តនៃការសិក្សា**

នៅឆ្នាំ១៩៩៦ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើជំនាញគីមីចំណីអាហារ។ ហើយនៅឆ្នាំ២០០៦ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញពាណិជ្ជសាស្ត្រ។

➢ **បទពិសោធន៍ការងារ**

លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅឆ្នាំ២០០៣ មានតួនាទីជាបុគ្គលិកកត់ត្រាទំនិញកុងតែន័រពីទីលាន។ ហើយនៅឆ្នាំ២០០៨ ដល់ឆ្នាំ២០១១ លោកមានតួនាទីជាប្រធានផ្នែកត្រួតពិនិត្យ និងរៀបចំកុងតែន័រដាក់តាម Lane។ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ លោកទទួលបានតួនាទីជានាយករងទទួលបន្ទុករួមចាត់ចែងត្រួតពិនិត្យភារកិច្ចទូទៅ នៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ។ ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកទទួលបានតួនាទីជានាយក នៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ ។

## ៣. ករណីអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធរបស់ក្រុមហ៊ុនផ្សេងទៀត

គិតត្រឹមឆ្នាំ២០២១ នេះ ពុំមានអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធរបស់ក្រុមហ៊ុនផ្សេងទៀតទេ។

| ល.រ | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬសហកម្មសិទ្ធករ |
|---|---|---|---|
| | | | |
| | | | |

## ៤. តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

ក្រុមប្រឹក្សាភិបាល ត្រូវបានប្រគល់នូវបេសកកម្មរួមសម្រាប់តម្រង់ទិស និងត្រួតពិនិត្យលើ **កសស** ។ ក្នុងក្របខណ្ឌនេះ ក្រុមប្រឹក្សាភិបាលមានតួនាទី ភារកិច្ច ការទទួលខុសត្រូវ ដូចខាងក្រោម ៖

- សម្រេចតាមសំណើរបស់អគ្គនាយកនូវ លក្ខន្តិកៈបុគ្គលិក រចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ **កសស** ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ជាធរមាន
- កំណត់ការចាត់ចែង និងភារកិច្ចទូទៅរបស់ **កសស**
- ពិនិត្យ និងអនុម័តលើផែនការអភិវឌ្ឍន៍ក្នុងក្របខណ្ឌនៃការតម្រង់ទិសរបស់ **កសស**
- ពិនិត្យ និងអនុម័តផែនការអាជីវកម្ម សេវាកម្ម ហិរញ្ញវត្ថុ និងវិនិយោគរបស់ **កសស**
- អនុម័តលើរបាយការណ៍របស់សវនករឯករាជ្យប្រចាំត្រីមាស និងប្រចាំឆ្នាំ
- អនុម័តលើរបាយការណ៍សកម្មភាពការងារប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ចាត់ចែងធ្វើឱ្យដំណើរការនូវគណៈកម្មាធិការ និងគណៈកម្មការដែលបានកំណត់ដោយអនុក្រឹត្យស្តីពីការបង្កើត **កសស** ឬ ដោយលក្ខន្តិកៈរបស់ **កសស**
- អនុម័តចំនួនក្របខណ្ឌបុគ្គលិក ដែលអនុញ្ញាតសម្រាប់ **កសស** និងការផ្តល់លាភការសម្រាប់បុគ្គលិក-និយោជិត ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់
- វាយតម្លៃក្នុងចន្លោះពេលទៀងទាត់នូវកម្រិតនៃការធ្វើឱ្យសម្រេចនូវគោលដៅ ដែលកំណត់ដោយ **កសស** និងដាក់ចេញនូវវិធានការសម្រាប់កែលម្អចាំបាច់
- ពិនិត្យ និងអនុម័តលើសំណើសុំកែសម្រួលលក្ខន្តិកៈ **កសស** និងលក្ខន្តិកៈបុគ្គលិក
- ពិនិត្យ និងអនុម័តថ្លៃឈ្នួលពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្មរបស់ **កសស**
- ពិនិត្យ និងអនុម័តលើគម្រោងបែងចែកប្រាក់ចំណេញ ឬគម្រោងបំពេញឱនភាព **កសស**
- ពិនិត្យ និងអនុម័តលើសំណូមពរក្នុងការបង្កើន ឬ បន្ថយដើមទុនរបស់ **កសស**
- ពិនិត្យ និងអនុម័តលើការអនុវត្តកិច្ចលទ្ធកម្មនានារបស់ **កសស**
- សម្រេចលើការបើក និងបិទគ្រប់ការិយាល័យ សាខា ទីភ្នាក់ងារ ឬ តំណាងទាំងអស់ដែលចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចគោលដៅ និងភារកិច្ចរបស់ **កសស**
- អនុម័តរាល់កិច្ចសន្យាទាំងឡាយណា ដែលមិនអាចអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ

ក្រុមប្រឹក្សាភិបាល អនុវត្តសិទ្ធិ និងអំណាចផ្សេងទៀត ដូចមានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសសាធារណៈ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

## ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ០៥-កុម្ភៈ-២០២១ | ពិភាក្សា និងអនុម័ត (សាមញ្ញ) | ឯ.ឧ លូ គឹមឈន់<br>ឯ.ឧ ស៊ុយ សាន<br>ឯ.ឧ ផាន់ ផល្លា<br>ឯ.ឧ សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. Hidetoshi KUME<br>លោក លូ លីខេង |
| ២ | ០៧-ឧសភា-២០២១ | ពិភាក្សា និងអនុម័ត (សាមញ្ញ) | ឯ.ឧ លូ គឹមឈន់<br>ឯ.ឧ ស៊ុយ សាន<br>ឯ.ឧ ផាន់ ផល្លា<br>ឯ.ឧ សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. Hidetoshi KUME<br>លោក លូ លីខេង |
| ៣ | ០៦-សីហា-២០២១ | ពិភាក្សា និងអនុម័ត (សាមញ្ញ) | ឯ.ឧ លូ គឹមឈន់<br>ឯ.ឧ ស៊ុយ សាន<br>ឯ.ឧ ផាន់ ផល្លា<br>ឯ.ឧ សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. Hidetoshi KUME<br>លោក លូ លីខេង |
| ៤ | ១៣-កញ្ញា-២០២១ | ពិភាក្សា និងអនុម័ត (វិសាមញ្ញ) | ឯ.ឧ លូ គឹមឈន់<br>ឯ.ឧ ស៊ុយ សាន<br>ឯ.ឧ ផាន់ ផល្លា<br>ឯ.ឧ សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. Hidetoshi KUME<br>លោក លូ លីខេង |

| | | | |
|---|---|---|---|
| ៥ | ២២-តុលា-២០២១ | ពិភាក្សា និងអនុម័ត (វិសាមញ្ញ) | ឯ.ឧ លូ គឹមឈន់<br>ឯ.ឧ ស៊ុយ សាន<br>ឯ.ឧ ផាន់ ផល្លា<br>ឯ.ឧ សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. Hidetoshi KUME<br>លោក លូ លីខេង |
| ៦ | ០៥-វិច្ឆិកា-២០២១ | ពិភាក្សា និងអនុម័ត (សាមញ្ញ) | ឯ.ឧ លូ គឹមឈន់<br>ឯ.ឧ ស៊ុយ សាន<br>ឯ.ឧ ផាន់ ផល្លា<br>ឯ.ឧ សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. Hidetoshi KUME<br>លោក លូ លីខេង |

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១. រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១.១ គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ហ៊ុន មុន្នីវណ្ណ | ប្រធាន | ០១-១០-២០២១ | ៣ | ៣ |
| ២ | ឯកឧត្តម សុខ សុភ័ក្ត្រ | អនុប្រធាន | ០១-១០-២០២១ | ៣ | ៣ |
| ៣ | លោក Hidetoshi KUME | សមាជិក | ០១-១០-២០២១ | ៣ | ៣ |
| ៤ | លោក ណុំ ស៊ីនិត | សមាជិក | ០១-១០-២០២១ | ៣ | ៣ |
| ៥ | លោក ទី សាគុណ | សមាជិក | ០១-១០-២០២១ | ៣ | ៣ |
| ៦ | លោក ម៉ែន ចាន់ | សមាជិក | ០១-១០-២០២១ | ៣ | ៣ |

❖ **តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម**

គណៈកម្មាធិការសវនកម្ម មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
- ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មខាងក្រៅ

- ធ្វើសវនកម្មលើសកម្មភាពការងារ និងអាជីវកម្ម **កសស**
- រាយការណ៍ជូនក្រុមប្រឹក្សាភិបាលលើសកម្មភាពការងាររបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល

❖ **លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម**

**ក្នុងឆ្នាំ២០២១ នេះ គណៈកម្មាធិការសវនកម្មសម្រេចបានលទ្ធផលការងារដូចខាងក្រោម៖**

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | សមាជិកគណៈ កម្មាធិការសវនកម្ម | តំណាងថ្នាក់ដឹកនាំ កសស |
|---|---|---|---|---|
| ១ | ០៤-កុម្ភៈ-២០២១ | - ប្រជុំឆ្លងរបាយការណ៍ សវនកម្ម ត្រីមាសទី៤ ឆ្នាំ២០២០ | លោក ហ៊ុន មុន្នីវណ្ណ<br>ឯកឧត្តម សុខ សុភ័ក្រ្ត<br>Mr. Hidetoshi KUME<br>លោក ណុំ ស៊ីនិត<br>លោក ទី សាគុណ<br>លោក ម៉ែន ចាន់ | ឯកឧត្តម ស៊ុយ សាន<br>លោក ជា យុទ្ធឌីកា<br>លោក វ័ត្ត សិលា<br>លោក ពិត ប្រាកដ<br>លោក ប៉ាត សិត<br>លោក សម សុភាព<br>លោក អ៊ុក សុមេធី<br>លោក សម វិសាល<br>លោក ជីវ ច័ន្ទសុភាព<br>លោក ជីវ ច័ន្ទសុធា<br>លោក ភាព ម៉េងស្រៀន |
| ២ | ០៥-សីហា-២០២១ | - ប្រជុំឆ្លងរបាយការណ៍ សវនកម្មត្រីមាសទី២ ឆ្នាំ២០២១ | លោក ហ៊ុន មុន្នីវណ្ណ<br>ឯ.ឧ សុខ សុភ័ក្រ្ត<br>Mr. Hidetoshi KUME<br>លោក ណុំ ស៊ីនិត<br>លោក ទី សាគុណ<br>លោក ម៉ែន ចាន់ | លោក ថៃ ឫទ្ធី<br>លោក វ័ត្ត សិលា<br>លោក ពិត ប្រាកដ<br>លោក ប៉ាត សិត<br>លោក សម សុភាព<br>លោក សម វិសាល<br>លោក ជីវ ច័ន្ទសុភាព<br>លោកស្រី ទូច វណ្ណា<br>លោក ជីវ ច័ន្ទសុធា<br>លោក ភាព ម៉េងស្រៀន |

| | | | | |
|---|---|---|---|---|
| ៣ | ០៤-វិច្ឆិកា-២០២១ | - ប្រជុំឆ្លងរបាយការណ៍សវនកម្មត្រីមាសទី៣ ឆ្នាំ២០២១ | លោក ហ៊ុន មុន្នីវណ្ណ<br>ឯ.ឧ សុខ សុភ័ក្ត្រ<br>Mr. Hidetoshi KUME<br>លោក ណុំ ស៊ីនិត<br>លោក ទី សាគុណ<br>លោក ម៉ែន ចាន់ | លោក ថៃ ឫទ្ធី<br>លោក វ័ត្ត សិលា<br>លោក ពិត ប្រាកដ<br>លោក សម សុភាព<br>លោក ជីវ ច័ន្ទសុភាព<br>លោក មាស សុវណ្ណា<br>លោក ជីវ ច័ន្ទសុធា |

## ១.២ គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯកឧត្តម សុខ សុភ័ក្ត្រ | ប្រធាន | ០១-១០-២០២១ | ៣ | ៣ |
| ២ | ឯកឧត្តម ស៊ុយ សាន | អនុប្រធាន | ០១-១០-២០២១ | ៣ | ៣ |
| ៣ | លោក លូ លីខេង | សមាជិក | ០១-១០-២០២១ | ៣ | ៣ |
| ៤ | លោក ណុំ ស៊ីនិត | សមាជិក | ០១-១០-២០២១ | ៣ | ៣ |
| ៥ | លោក វ័ត្ត សិលា | សមាជិក | ០១-១០-២០២១ | ៣ | ៣ |

### ❖ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំង និងលាភការ

គណៈកម្មាធិការតែងតាំងនិងលាភការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យ និងផ្តល់អនុសាសន៍លើលក្ខខណ្ឌគុណវឌ្ឍ និងនីតិវិធីនៃការជ្រើសរើសបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់
- វាយតម្លៃបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីដាក់ស្នើសុំទៅក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើយន្តការ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មាធិការនានា
- រៀបចំនីតិវិធីពិនិត្យ និងផ្តល់អនុសាសន៍លើលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

❖ លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំង និងលាភការ

ក្នុងឆ្នាំ២០២១ នេះ គណៈកម្មាធិការតែងតាំង និងលាភការសម្រេចបានលទ្ធផលការងារដូចខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | សមាជិកគណៈកម្មាធិការតែងតាំងនិងលាភការ | តំណាងថ្នាក់ដឹកនាំកសស |
|---|---|---|---|---|
| ១ | ០៤-កុម្ភៈ-២០២១ | - ប្រជុំឆ្លងរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ ២០២០ | ឯ.ឧ សុខ សុភ័ក្រ្ត<br>ឯ.ឧ ស៊ុយ សាន<br>លោក លូ លីខេង<br>លោក ណុំ ស៊ីនិត<br>លោក វ័ត្ន សិលា | លោក ឈុន ហុង<br>លោក ប៉ាត សិត<br>លោក ពិត ប្រាកដ |
| ២ | ០៥-សីហា-២០២១ | - ប្រជុំឆ្លងរបាយការណ៍ប្រចាំត្រីមាសទី២ ឆ្នាំ ២០២១ | ឯ.ឧ សុខ សុភ័ក្រ្ត<br>ឯ.ឧ ស៊ុយ សាន<br>លោក លូ លីខេង<br>លោក ណុំ ស៊ីនិត<br>លោក វ័ត្ន សិលា | លោក ពិត ប្រាកដ<br>លោក អ៊ូ សុវណ្ណឫទ្ធិ<br>លោក សាន ឈន់<br>លោក តាំង ស៊ុនងួន |
| ៣ | ០៤-វិច្ឆិកា-២០២១ | - ប្រជុំឆ្លងរបាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ ២០២១ | ឯ.ឧ សុខ សុភ័ក្រ្ត<br>ឯ.ឧ ស៊ុយ សាន<br>លោក លូ លីខេង<br>លោក ណុំ ស៊ីនិត<br>លោក វ័ត្ន សិលា | លោក ពិត ប្រាកដ<br>លោក អ៊ូ សុវណ្ណឫទ្ធិ<br>លោក សាន ឈន់ |

## ១.៣ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯ.ឧ. ផាន់ ផល្លា | ប្រធាន | ០១-១០-២០២១ | ៣ | ៣ |
| ២ | ឯ.ឧ. ស៊ុយ សាន | អនុប្រធាន | ០១-១០-២០២១ | ៣ | ៣ |
| ៣ | លោក Hidetoshi KUME | អនុប្រធាន | ០១-១០-២០២១ | ៣ | ៣ |
| ៤ | ឯ.ឧ. សុខ សុភ័ក្រ្ត | សមាជិក | ០១-១០-២០២១ | ៣ | ៣ |
| ៥ | លោក ហ៊ុន មុន្នីវណ្ណ | សមាជិក | ០១-១០-២០២១ | ៣ | ៣ |
| ៦ | លោក ណុំ ស៊ីនិត | សមាជិក | ០១-១០-២០២១ | ៣ | ៣ |

## ❖ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- វិភាគហានិភ័យរួមមាន ការពិពណ៌នាហានិភ័យ ការកំណត់អត្តសញ្ញាណហានិភ័យ
- ប៉ាន់ស្មានហានិភ័យ
- វាយតម្លៃហានិភ័យ
- លើកវិធានការទប់ទល់ហានិភ័យ
- តាមដានអំពីហានិភ័យ
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

## ❖ លទ្ធផលការងាររបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

**ក្នុងឆ្នាំ២០២១ នេះ គណៈកម្មាធិការគ្រប់គ្រងហានិភ័យសម្រេចបានលទ្ធផលការងារដូចខាងក្រោម៖**

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ | តំណាងថ្នាក់ដឹកនាំកសស |
|---|---|---|---|---|
| ១ | ០៤-កុម្ភៈ-២០២១ | - ប្រជុំឆ្លងរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ ២០២០ | ឯ.ឧ. ផាន់ ផល្លា<br>ឯ.ឧ ស៊ុយ សាន<br>លោក Hidetoshi KUME<br>ឯ.ឧ សុខ សុភ័ក្រ្ត<br>លោក ហ៊ុន មុន្នីវណ្ណ<br>លោក ណុំ ស៊ីនិត | លោក ថៃ ឬទ្ធី<br>លោក ជា យុទ្ធឌីកា<br>លោក ទី សាគុណ<br>លោក វ័ត្ន សិលា<br>លោក ពិត ប្រាកដ<br>លោក សម សុភាព<br>លោក ស៊ុក កុលចិន្តា<br>លោក អ៊ូ សុវណ្ណឬទ្ធិ<br>លោក សាន ឈន់<br>លោក អ៊ុក សុមេធី<br>លោក សម វិសាល |
| ២ | ០៥-សីហា-២០២១ | - ប្រជុំឆ្លងរបាយការណ៍ប្រចាំត្រីមាសទី២ ឆ្នាំ ២០២១ | ឯ.ឧ. ផាន់ ផល្លា<br>ឯ.ឧ ស៊ុយ សាន<br>លោក Hidetoshi KUME<br>ឯ.ឧ សុខ សុភ័ក្រ្ត<br>លោក ហ៊ុន មុន្នីវណ្ណ<br>លោក ណុំ ស៊ីនិត | លោក ថៃ ឬទ្ធី<br>លោក វ័ត្ន សិលា<br>លោក ពិត ប្រាកដ<br>លោក សូ សៀង<br>លោក សម សុភាព<br>លោក អ៊ូ សុវណ្ណឬទ្ធិ<br>លោក សាន ឈន់<br>លោក តាំង ស៊ុនងួន |

| | | | | |
|---|---|---|---|---|
| ៣ | ០៤-វិច្ឆិកា-២០២១ | - ប្រជុំផ្លូវការបាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ ២០២១ | ឯ.ឧ. ផាន់ ផល្លា<br>ឯ.ឧ ស៊ុយ សាន<br>លោក Hidetoshi KUME<br>ឯ.ឧ សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>លោក ណុំ ស៊ីនិត | លោក ថៃ ឫទ្ធី<br>លោក វ័ត្ន សិលា<br>លោក ពិត ប្រាកដ<br>លោក សូ សៀង<br>លោក សម សុភាព<br>លោក ស៊ុក កុលចិន្តា<br>លោក អ៊ុក សុមេធី<br>លោក អ៊ូ សុវណ្ណឫទ្ធិ<br>លោក សាន ឈន់ |

## ១.៤ គណៈកម្មាធិការផ្សេងទៀត

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| | | | | | |

❖ **តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការផ្សេងទៀត**

គិតត្រឹមឆ្នាំ២០២១ នេះ **កសស** មិនទាន់មានគណៈកម្មាធិការផ្សេងទៀតនៅឡើយទេ ។

❖ **លទ្ធផលការងាររបស់គណៈកម្មាធិការផ្សេងទៀត**

គិតត្រឹមឆ្នាំ២០២១ នេះ មិនទាន់មានលទ្ធផលការងាររបស់ កម្មាធិការផ្សេងទៀតទេ ។

## ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

គិតត្រឹមឆ្នាំ២០២១ នេះ មិនមានការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការទេ។

# គ. លាភការ ឬប្រាក់បំណាច់

## ១. គោលនយោបាយសង្ខេបស្តីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

❖ លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាលរបស់ **កសស** ត្រូវបានផ្តល់ជូនដូចខាងក្រោម៖

- ការឧបត្ថម្ភលើមធ្យោបាយធ្វើដំណើរ
- ការឧបត្ថម្ភទូរសព្ទ
- ការឧបត្ថម្ភម៉ោងប្រជុំ
- ប្រាក់ឧបត្ថម្ភផ្សេងៗ

❖ លាភការ ឬប្រាក់បំណាច់សម្រាប់បុគ្គលិកជាន់ខ្ពស់របស់ **កសស** ត្រូវបានផ្តល់ជូនដូចខាងក្រោម៖

- ប្រាក់បៀវត្សរ៍សុទ្ធ

- ប្រាក់បៀវត្សរ៍ទិន្នផល
- ប្រាក់មុខងារ
- ប្រាក់វិភាជន៍គ្រួសារ
- ប្រាក់ថ្លៃបាយ
- ប្រាក់បូណឹស
- ប្រាក់ថ្ងៃបុណ្យ

## ២. បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

| ល.រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ១.២២៤.000.000,00 រៀល | |
| ២ | អភិបាលប្រតិបត្តិ | ៣៦0.000.000,00 រៀល | |
| ៣ | បុគ្គលិកជាន់ខ្ពស់ | ២.៥0៩.១១៤.000,00 រៀល | |
| ៤ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥រូប | ៣៧៧.១៣៥.000,00 រៀល | |

## ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ

គិតត្រឹមឆ្នាំ២០២១ នេះ **កសស** មិនបានធ្វើការវាយតម្លៃលទ្ធផលប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាភិបាល អភិបាល គណៈកម្មាធិការ និងនាយកប្រតិបត្តិទេ។

## ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

នៅក្នុងឆ្នាំ២០២១ នេះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានបញ្ជូនថ្នាក់ដឹកនាំ អភិបាល និងបុគ្គលិកជាន់ខ្ពស់ទៅចូលរួមវគ្គបណ្តុះបណ្តាលដូចខាងក្រោម៖

- វគ្គបណ្តុះបណ្តាល ស្តីពីក្បួនខ្នាតបច្ចេកទេស និងសុវត្ថិភាព ជូនអ្នកបើកបររថយន្តដឹកកុងតែន័រ (Platform)
- វគ្គបណ្តុះបណ្តាល បច្ចេកទេសស្តីពី ការងារកណ្ណធារកិច្ច និងការប្រើប្រាស់ប្រព័ន្ធ VTMS
- វគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តតេស្តរហ័សកូវីដ-១៩ ( Rapid Test) - វគ្គ ១ និងវគ្គ ២
- Group Training Course "Capacity Development for Port Facility Security" for Fiscal Year 2021 - **លោក យាន ទេពពិសិដ្ឋ**
- Group Training Course "Port Maintenance Planning" for Fiscal Year 2021 - **លោក កែវ យុន**

- វគ្គបណ្តុះបណ្តាលស្តីពី Hyperflex Server Cisco ជូនដល់ មន្ត្រី-បុគ្គលិក នៃនាយកដ្ឋានព័ត៌មានវិទ្យា
- វគ្គបណ្តុះបណ្តាល Deloitte Learning Solutions (Impairment Issue in the midst of Volatility)
- វគ្គបណ្តុះបណ្តាល ស្តីពី វិធីសាស្ត្រស្រាវជ្រាវ
- វគ្គបណ្តុះបណ្តាលស្តីពី ពន្ធដារកម្ពុជា (Cambodian TAX)
- វគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិកត្រូនិកនៅកំពង់ផែ(Port EDI)
- The 4th Expert Group Meeting on Advance Personnel Training Program for Vessel Traffic Services VTS 2020-2021
- វគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពជណ្តើរនាវា ជូនកណ្ណធារ ( Ship Pilot )

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្ត

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌ សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

### គោលការណ៍នៃក្រមសីលធម៌

### ប្រការ ១. សេចក្តីផ្តើម

ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរួមទាំងប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ និងជាការប្តេជ្ញាជម្រុញឱ្យមានការអនុវត្តន៍ការងារប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌ល្អ ក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ **កសស** បានអនុម័ត ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តឱ្យមានភាពស្មោះត្រង់ និងឥរិយាបថប្រកបដោយសីលធម៌ក្នុងការធ្វើអាជីវកម្ម ដើម្បីធានា ឱ្យបាននូវសមភាព និងជៀសវាងអំពីទំនាស់ផលប្រយោជន៍ ។
- លើកទឹកចិត្តក្នុងការផ្តល់ព័ត៌មានចាំបាច់នានាដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានឱ្យបានពេញលេញ ច្បាស់លាស់ ត្រូវត្រឹម និងទាន់ពេល ។
- លើកទឹកចិត្តដល់ការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។
- ធានាការពារផលប្រយោជន៍អាជីវកម្មស្របច្បាប់របស់ក្រុមហ៊ុន រួមបញ្ចូលទាំងកាលានុវត្តភាពអាជីវកម្ម ទ្រព្យសកម្ម និងទ្រព្យអរូបិយ និងព័ត៌មានសម្ងាត់របស់ក្រុមហ៊ុន ។
- បញ្ចៀសនូវអាកប្បកិរិយាមិនត្រឹមត្រូវ ឬទង្វើឆ្នាំឆ្លងទាំងឡាយ ។

អាជីវកម្មរបស់ **កសស** ត្រូវស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំទូទៅដោយក្រុមប្រឹក្សាភិបាល។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានការទទួលខុសត្រូវជាចម្បង ក្នុងការសម្រេចចិត្តអាជីវកម្មដែលខ្លួនជឿជាក់ថាផ្តល់ប្រយោជន៍ល្អដល់ **កសស** និងសម្រាប់ភាគហ៊ុនិកទាំងអស់របស់ **កសស** ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ត្រូវយល់ច្បាស់ពីក្រមសីលធម៌ ហើយត្រូវប្រកាន់ខ្ជាប់នូវគោល ការណ៍ និងវិធានដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ។

## ប្រការ ២. និយមន័យ

នៅក្នុងបរិបថនៃក្រមសីលធម៌ ពាក្យខាងក្រោមត្រូវបានឱ្យនិយមន័យដូចតទៅ៖

- **ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ៖** សំដៅដល់រាល់ច្បាប់ និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា រួមមានជាអាទិ៍ ច្បាប់ អនុក្រឹត្យ ប្រកាស វិធាន និងគោលការណ៍ណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចដូចជា **ន.ម.ក** និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហៅកាត់ថា **ផ.ម.ក** ដែលច្បាប់ និងបទប្បញ្ញត្តិ ទាំងនោះត្រូវអនុវត្តន៍ទៅលើ **កសស** អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ **កសស** ។
- **អភិបាល ៖** សំដៅដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ **កសស** រួមបញ្ចូលទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ និងអភិបាលឯករាជ្យ ។
- **បុគ្គលិកជាន់ខ្ពស់ ៖** សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយករហូតដល់អគ្គនាយក រួមទាំងប្រធានលេខាធិការ និងអ្នកដែលមានមុខតំណែងសំខាន់ៗផ្សេងទៀតក្នុង **កសស** ដែល កំណត់ដោយក្រុមប្រឹក្សាភិបាល **កសស** ។

## ប្រការ ៣. ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ

ក្នុងពេលបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនអភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ត្រូវអនុវត្ត និងព្យាយាមធ្វើឱ្យ **កសស** អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយបានដឹងពីព័ត៌មានដែលខ្លួនជឿជាក់ថា អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតណាមួយបានបំពានច្បាប់ និងបទប្បញ្ញត្តិជាធរមាន អភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលបានដឹងត្រូវផ្តល់ព័ត៌មានជូនប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយក ប្រធានគណៈកម្មាធិការសវនកម្ម ឬសវនកម្មផ្ទៃក្នុង ។

## ប្រការ ៤. អំពីទំនាស់ផលប្រយោជន៍

បន្ថែមលើបទប្បបញ្ញត្តិទាំងឡាយនៃមាត្រា ១៣៤ ១៤៥ ១៣៦ និងមាត្រា ១៣៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងនូវរាល់អំពើទំនាស់ផលប្រយោជន៍ដែល អាចកើតមានជាមួយ **កសស** ។

ជាទូទៅ ទំនាស់ផលប្រយោជន៍កើតឡើងនៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬអាចនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់ ៖

- **ក.** ផលប្រយោជន៍ទូទៅ ឬអាជីវកម្មរបស់ **កសស** ។
- **ខ.** លទ្ធភាពរបស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ផ្សេងទៀតក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវ របស់ខ្លួន ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ **កសស** ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈពីប្រតិបត្តិការ ឬទំនាក់ទំនងណាមួយដែលខ្លួនគិតថានឹងនាំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយ **កសស** តាមការកំណត់របស់ **ន.ម.ក** ឬ **ផ.ម.ក** ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ **កសស** ត្រូវបង្ហាញនូវផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅ **កសស** ស្នើរឱ្យមានសេចក្តីប្រកាសដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលក្នុងករណីដែល ៖

ក. អភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះជាភាគីនៃកិច្ចសន្យា ឬជាអ្នកស្នើធ្វើជាមួយនឹង **កសស**

ខ. អភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះមានផលប្រយោជន៍សំខាន់ជាមួយនឹងបុគ្គល ឬនីតិបុគ្គលដែលជាភាគីក្នុងកិច្ចសន្យា ឬភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយ **កសស** ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជា ធរមាន រួមទាំងប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជា សាធារណៈអភិបាលឯករាជមិនត្រូវមានផលប្រយោជន៍ណាមួយនៅក្នុង **កសស** ដែលធ្វើឱ្យប៉ះពាល់ឯករាជ របស់ខ្លួន និងមិនត្រូវកាន់កាប់ភាគហ៊ុនលើសពី ១% (មួយភាគរយ) នៃភាគហ៊ុនរបស់ **កសស** ឡើយ ។

## ប្រការ ៥. កាលានុវត្តភាពអាជីវកម្ម

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ជាអទិភាពដល់ផលប្រយោជន៍ស្របច្បាប់របស់ **កសស** នៅពេលសមស្រប ។

➢ **អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាង ៖**

ក. ឆ្លៀតឱកាសធ្វើកិច្ចការដើម្បីផលប្រយោគន៍ផ្ទាល់ខ្លួន ដែលខ្លួនបានដឹងក្នុងពេលអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុង **កសស** ។

ខ. ប្រើប្រាស់ទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ **កសស** ឬឋានៈ និងមុខតំណែងរបស់ខ្លួនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។

គ. ប្រកួតប្រជែងជាមួយ **កសស** ។

ក្រុមប្រឹក្សាភិបាល និងកំណត់ពីទង្វើដែលផ្ទុយពីខ្លឹមសារនៃប្រការនេះដោយពិចារណាលើអង្គហេតុ និងស្ថានការណ៍ដែលពាក់ព័ន្ធទាំងឡាយនៃទង្វើនោះ ។

## ប្រការ ៦. ទំនាក់ទំនងដោយស្មើភាព

នៅក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវធ្វើឱ្យមានភាពស្មើគ្នាក្នុងការទំនាក់ទំនងរវាងគ្នា និងជាមួយអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង អ្នកម៉ៅការ និងនិយោជិតរបស់ **កសស** ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកប្រយោជន៍ពីបុគ្គលណាម្នាក់ ដោយប្រើប្រាស់ឧបាយកល ការមិនស្មោះត្រង់ ការលាក់បាំង ការបំភ័ន្ត ព័ត៌មានសំខាន់ៗ ការបង្ហាញហេតុការណ៍ដែលខុសពីការពិត ឬដោយអំពើមិនស្មោះត្រង់ផ្សេងទៀតក្នុងអាជីវកម្ម ។

ការប្រើប្រាស់សិទ្ធអំពីព័ត៌មានសម្ងាត់នៃអាជីវកម្មរបស់ **កសស** ឬការបញ្ចុះបញ្ចូលអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ **កសស** ទាំងអតិត និងបច្ចុប្បន្នឱ្យទម្លាយនូវព័ត៌មានទាំងនោះត្រូវបាន ហាមឃាត់ជាដាច់ខាត ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដោយសុច្ចរិត និងដើម្បីផលប្រយោជន៍របស់ **កសស** និងភាគហ៊ុនិកទាំងអស់របស់ **កសស** ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួនជាអភិបាល ឬជាបុគ្គលិកជាន់ខ្ពស់ និងមិនត្រូវទទួលអំណោយណាមួយពីតតិយជនដោយសារមុខតំណែងជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ។

## ប្រការ ៧. ការការពារ និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ កសស

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជំរុញឱ្យមានការត្រួតពិនិត្យ និងការប្រើប្រាស់ឱ្យបានត្រឹមត្រូវដោយមានការទទួលខុសត្រូវនូវទ្រព្យសម្បត្តិរបស់ **កសស** រួមទាំងទ្រព្យរូបិយ និងទ្រព្យអរូបិយ ។

ទ្រព្យសម្បត្តិរបស់ **កសស** មានដូចជា ព័ត៌មាន សម្ភារៈ គ្រឿងបរិក្ខារ កម្មសិទ្ធបញ្ញា ឧបករណ៍ ប្រភពធនធាន ប្រព័ន្ធព័ត៌មានវិទ្យា និងទ្រព្យដទៃទៀតដែលជាកម្មសិទ្ធរបស់ **កសស** ឬទ្រព្យដែល **កសស** ជួលពីគេ ឬទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ **កសស** ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអាជីវកម្ម ស្របច្បាប់របស់ **កសស** តែប៉ុណ្ណោះ ។

## ប្រការ ៨. បណ្តឹងពាក់ព័ន្ធនឹងគណនេយ្យ

គណៈកម្មាធិការសវនកម្ម (ប្រសិនបើមាន) ឬសវនករផ្ទៃក្នុងរបស់ **កសស** ត្រូវទទួលខុសត្រូវក្នុងការការរៀបចំនីតិវិធីសមស្របមួយសម្រាប់ទទួលពាក្យបណ្តឹង និងរក្សាទុកនូវពាក្យបណ្តឹង និងពិនិត្យមើលពាក្យបណ្តឹងទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យគណនេយ្យផ្ទៃក្នុង ឬបញ្ហាផ្សេងៗទៀតដែលទាក់ទងទៅនឹងសវនកម្ម ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់អាចដាក់ពាក្យបណ្តឹងពីបញ្ហាខាងលើ ទៅគណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ **កសស**។ ការស្នើសុំឱ្យពិនិត្យបណ្តឹងជាសម្ងាត់អាចធ្វើឡើងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ប្រការ ៩. ការលើកទឹកចិត្តឱ្យរាយការណ៍ពីទង្វើខុសច្បាប់ ឬអសីលធម៌

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវខិតខំជម្រុញឱ្យ **កសស** ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ទៅនាយក ឬបុគ្គលដែលមានសមត្ថកិច្ចនៅក្នុង **កសស** នៅពេលដែលទង្វើខុសច្បាប់ ឬអសីលធម៌ណាមួយអាចនឹងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរដល់អាជីវកម្ម និងកេរ្តិ៍ឈ្មោះរបស់ **កសស** ឬវាអាចនឹងនាំឱ្យមានការទទួលខុសត្រូវធ្ងន់ធ្ងរតាមផ្លូវច្បាប់ ។

## ប្រការ ១០. ការជួញដូរផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្ត និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិជាធរមាន បទបញ្ជាផ្ទៃក្នុង និងគោលនយោបាយ **កសស** ពាក់ព័ន្ធនឹងការលក់-ទិញភាគហ៊ុនរបស់ **កសស** ។

## ប្រការ ១១. ការរក្សាការសម្ងាត់

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវរក្សាការសម្ងាត់នៃព័ត៌មានសម្ងាត់របស់ **កសស** ដែលខ្លួនបានដឹង លើកលែងតែក្នុងករណីដែល **កសស** អនុញ្ញាតឱ្យផ្តល់ព័ត៌មាន ឬការផ្តល់ព័ត៌មាននេះត្រូវបានតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថា "ព័ត៌មានសម្ងាត់" រួមមានជាអាទិ៍ ព័ត៌មានមិនមែនសាធារណៈដែលអាចត្រូវបានប្រើដោយគូប្រកួតប្រជែងរបស់ **កសស** ឬព័ត៌មានមិនមែនសាធារណៈដែលធ្វើឱ្យប៉ះពាល់ដល់ **កសស** ឬអតិថិជនរបស់ **កសស** ប្រសិនបើព័ត៌មាននោះត្រូវបានបង្ហាញ ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវពិភាក្សាជាមុនជាមួយនឹងអគ្គនាយក ឬប្រធានក្រុមប្រឹក្សាភិបាលប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះគិតថាខ្លួនមានកាតព្វកិច្ចតាមច្បាប់ក្នុងការបង្ហាញព័ត៌មានសម្ងាត់នោះ។

## ប្រការ ១២. ការផ្តល់ព័ត៌មាន

អភិបាល និងបុគ្គលិកជាន់តម្រូវឱ្យយល់ច្បាស់ពីនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ **កសស** ដើម្បីឱ្យចេញសេចក្តីប្រកាសជាសាធារណៈ របាយការណ៍ និងឯកសារផ្តល់ព័ត៌មានដែលត្រូវចុះបញ្ជីជាមួយ អាជ្ញាធររដ្ឋរួមបញ្ចូលទាំង **ន.ម.ក** អាចរៀបចំធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរួមទាំង គោលការណ៍ណែនាំរបស់ **ន.ម.ក** និង **ផ.ម.ក** ។

ម៉្យាងវិញទៀតក្នុងទំហំនៃតួនាទី និងការទទួលខុសត្រូវរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមានអំណាចដឹកនាំ ឬគ្រប់គ្រងការចុះបញ្ជីឯកសារជាមួយ **ន.ម.ក** និង / ឬ **ផ.ម.ក** ឬការជូនដំណឹងជាសាធារណៈផ្សេងៗទៀតរបស់ **កសស** ពាក់ព័ន្ធអាជីវកម្មទូទៅ លទ្ធផល លក្ខខណ្ឌ និងលទ្ធភាពហិរញ្ញវត្ថុត្រូវពិភាក្សាជាមួយនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ផ្សេងទៀត និងជាមួយនិយោជិតពាក់ព័ន្ធហើយចាត់វិធានការសមស្របសម្រាប់នីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានដើម្បីឱ្យការផ្តល់ព័ត៌មានធ្វើបានពេញលេញ ច្បាស់លាស់ត្រឹមត្រូវទាន់ពេល និងអាចយល់បាន ។

ក្នុងទំហំដែលពាក់ព័ន្ធទៅនឹងនីតិវិធី និងការត្រួតពិនិត្យ ការផ្តល់ព័ត៌មានរបស់ **កសស** អភិបាល និងបុគ្គលិកជាន់ខ្ពស់ម្នាក់ៗ ៖

- ត្រូវយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវនៃការផ្តល់ ព័ត៌មានរបស់ **កសស** ក៏ដូចជាប្រតិបត្តិការអាជីវកម្ម និងហិរញ្ញវត្ថុរបស់ **កសស** ។
- មិនត្រូវធ្វើសេចក្តីថ្លែងខុសពីការពិត ឬធ្វើឱ្យអ្នកដទៃថ្លែងខុសពីការពិតទាក់ទងអំពីព័ត៌មានរបស់ **កសស** ប្រាប់អ្នកដទៃ ទោះបីជាអ្នកនោះនៅក្នុង ឬក្រៅ **កសស** រួមទាំងសវនករឯករាជ្យ និយ័តករ របស់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត ។

## ប្រការ ១៣. វិសោធនកម្ម និងការលើកលែង

ក្រមសីលធម៌នេះអាចត្រូវបានធ្វើវិសោធនកម្ម ឬលើកលែងមិនអនុវត្តដោយក្រុមប្រឹក្សាភិបាលរបស់ **កសស** ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាវិធានទូទៅ

ក្រុមប្រឹក្សាភិបាលនឹងមិនផ្តល់ការលើកលែងមិនអនុវត្តប្រការណាមួយនៃក្រមសីលធម៌នេះឡើយ ប្រសិនបើគ្មានមូលហេតុសមស្រប និងចាំបាច់នោះទេ ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានកាតព្វកិច្ចយល់ដឹងពីក្រមសីលធម៌ និងស្វែងរកការពន្យល់ និងការផ្តល់ប្រឹក្សាបន្ថែមទាក់ទងនឹងការបកស្រាយខ្លឹមសារបន្ថែម និងលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌ជាពិសេសនៅពេលមានហេតុការណ៍ណាមួយដែលអាចមានទំទាស់ជាមួយនឹងក្រមសីលធម៌ ។

### ការអនុវត្តក្រមសីលធម៌

ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ **កសស** នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ និងមានអានុភាពអនុវត្តចាប់ពី **កសស** ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈដោយ **ន.ម.ក** និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅ **ផ.ម.ក** ។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានអនុម័តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដោយត្រូវបានផ្សព្វផ្សាយ និងមានបង្ហាញក្នុងរបាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២១ នេះ ជូនដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និយោជិត វិនិយោគិនរបស់ **កសស** និងសាធារណៈជន ។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

សម្រាប់យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច កំពង់ផែស្វយ័តក្រុងព្រះសីហនុបានប្រគល់ភារកិច្ចជូនទៅនាយកដ្ឋានសវនកម្មផ្ទៃក្នុងធ្វើការត្រួតពិនិត្យជាប្រចាំ ក៏ដូចជាជម្រុញ និងលើកទឹកចិត្តដល់គ្រប់និយោជិតរបស់ **កសស** ឱ្យរាយការណ៍ពីភស្តុតាងនៃទង្វើខុសច្បាប់ ឬអសីលធម៌ ទៅនាយកដ្ឋាន ឬបុគ្គលដែលមានសមត្ថកិច្ចនៅក្នុង **កសស** នៅពេលដែលទង្វើខុសច្បាប់ ឬអសីលធម៌ណាមួយនេះអាចនឹងធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរដល់អាជីវកម្ម និងកេរ្តិ៍ឈ្មោះរបស់ **កសស** ឬវាអាចនឹងនាំឱ្យមានការទទួលខុសត្រូវធ្ងន់ធ្ងរតាមផ្លូវច្បាប់ ។

## ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១. គោលនយោបាយរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

គិតត្រឹមឆ្នាំ២០២១ នេះ **កសស** មិនទាន់មានគោលនយោបាយសម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធទេ ។

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន និងច្រើនលើសលុប | |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | |
| ៧ | ផ្សេងៗ | |

## ២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ

គិតត្រឹមឆ្នាំ២០២១ នេះ **កសស** មិនមានប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធនោះទេ ។

| ល.រ | ឈ្មោះភាគីជាប់ពាក់ព័ន្ធ | ប្រភេទប្រតិបត្តិការ | ទំហំប្រតិបត្តិការ | សង្ខេបអំពីប្រតិបត្តិការ |
|---|---|---|---|---|
| | | | | |
| | | | | |

# ផ្នែកទី៤. ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

## ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

គណៈកម្មាធិការគ្រប់គ្រងហានិភ័យបានអង្កេតនឹងតាមដានអំពីស្ថានភាពហានិភ័យរបស់ **កសស** និងបង្ហាញពីទិសដៅសម្រាប់សកម្មភាពទាំងឡាយ ដើម្បីកាត់បន្ថយហានិភ័យដែលអាចផ្តល់ផលអាក្រក់ទៅដល់ **កសស** ក្នុងការសម្រេចគោលដៅឱ្យនៅក្នុងកម្រិតមួយដែលអាចទទួលយកបាន។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យនឹងបន្តសម្របសម្រួលកែច្នៃឱ្យល្អជាងមុនលើសម្ថភាពគ្រប់គ្រងហានិភ័យរបស់ខ្លួន លើសពីនេះទៅទៀតនឹងបន្តគាំទ្រការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការសវនកម្មក្នុងការតាមដាន និងវាយតម្លៃដូចដែលបានកំណត់ទៅតាមនិយ័តករមូលបត្រកម្ពុជា "គោលការណ៍ និងគោលនយោបាយក្នុងការគ្រប់គ្រងដំណើរការដោយវាយតម្លៃហានិភ័យ និងការគ្រប់គ្រងដែលត្រូវបានអនុវត្ត" ។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យបានអនុវត្ត និងចាត់ចែងកាតព្វកិច្ចដើម្បីកំណត់អត្តសញ្ញាណ និងកំណត់អាទិភាពហានិភ័យអាជីវកម្មដូចខាងក្រោម៖

- ពិនិត្យទៅលើការកំណត់ហានិភ័យរបស់ **កសស** ដើម្បីយល់ពីស្ថានភាពនាពេលបច្ចុប្បន្ន និងពេលដែលកំពុងកើតឡើង។

- ធានាគំលាតនូវប្រសិទ្ធភាពដែលមានការបង្ហាញសអំពីហានិភ័យដែលមានកម្រិតខ្ពស់ និងបង្ហាញទិសដៅសម្រាប់ការបែងចែកនូវធនធាន និងកាតព្វកិច្ចក៏ដូចជាសកម្មភាពដែលបង្ហាញអំពីហានិភ័យរបស់អាជីវកម្ម។
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ បង្កើតហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងទៅលើហានិភ័យ និងផ្តល់នូវសេចក្តីណែនាំទាក់ទងទៅនឹងការគ្រប់គ្រងប្រតិបត្តិការហានិភ័យ ដោយរួមបញ្ចូលទាំងប្រព័ន្ធដំណើរការរបស់ **កសស**។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មិនមានកាតព្វកិច្ចទទួលខុសត្រូវលើសកម្មភាពប្រចាំថ្ងៃដែលពាក់ព័ន្ធទៅលើការគ្រប់គ្រងហានិភ័យ ឬកាត់បន្ថយហានិភ័យទាំងឡាយនោះទេ។ ទោះយ៉ាងណាក៏ដោយ សមាជិកនៅក្នុងគណៈកម្មការអាចមានការងារគ្រប់គ្រងហានិភ័យដែលជាផ្នែកមួយនៅក្នុងរមូលដ្ឋានរបស់ **កសស**។

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

សវនកបានវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយផ្អែកលើការពិនិត្យសមត្ថភាពនៃដំណើរការគ្រប់គ្រង ដើម្បីសម្រេចបាននូវគោលបំណងស្របតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់សវនដ្ឋាន។

## គ. ការធ្វើសវនកម្ម

### ១. សវនកម្មផ្ទៃក្នុង

### ១.១ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង

- ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
- ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មខាងក្រៅ
- ធ្វើសវនកម្មលើសកម្មភាពការងារ និងអាជីវកម្ម **កសស**
- រាយការណ៍ជូនក្រុមប្រឹក្សាភិបាលលើសកម្មភាពការងាររបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល

### ១.២ ការតែងតាំង និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

| ល.រ | ឈ្មោះ | កាលបរិច្ឆេទតែងតាំង | កាលបរិច្ឆេទដកហូត/លាលែង | មូលហេតុ |
|---|---|---|---|---|
| ១ | ម៉ែន ចាន់ | ២៥-១២-២០១៥ | | |
| ២ | ជីវ ចាន់សុភាព | ១០-មេសា-២០២០ | | |
| ៣ | ហោ សុធី | ១០-មេសា-២០២០ | | |

### ១.៣ ការតែងតាំងថ្មីប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

សម្រាប់ឆ្នាំ២០២១ នេះ **កសស** មិនមានការតែងតាំងប្រធាន/អនុប្រធានសវនករផ្ទៃក្នុងថ្មីទេ ។

| ល.រ | ឈ្មោះ | កាលបរិច្ឆេទតែងតាំងថ្មី | មូលហេតុ |
| --- | --- | --- | --- |
| | | | |

## ២. សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម | តម្លៃសេវាមិនមែនសវនកម្ម |
| --- | --- | --- | --- | --- |
| ១ | Pricewaterhouse | ០៦.០៦.២០១៧ | ៩៧.៨៥០,០០ ដុល្លារ | |

❖ **មូលហេតុនៃការផ្លាស់ប្តូរ ការផ្អាក និងការបញ្ឈប់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ**

សម្រាប់ឆ្នាំ២០២១ នេះ **កសស** មិនមានការផ្លាស់ប្តូរ ការផ្អាក និងការបញ្ឈប់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រនោះទេ ។

# ផ្នែកទី៥. ភាគីពាក់ព័ន្ធ

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
| --- | --- | --- | --- |
| ១ | សុខមាលភាពរបស់អតិថិជន | យកចិត្តទុកដាក់ និងបំពេញតម្រូវការអតិថិជន | ផ្តល់សេវាកម្មជូនអតិថិជនអោយបានទាន់ពេលវេលា |
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ | អនុវត្តនីតិវិធីលទ្ធកម្ម | ដេញថ្លៃ និងពិគ្រោះថ្លៃ |
| ៣ | ការគ្រប់គ្រង និងការការពារនិយោជិត | តំណាងនិយោជិត | បោះឆ្នោតរើសតំណាងនិយោជិត |
| ៤ | ការគាំពារបរិស្ថាន | ដើម្បីគ្រប់គ្រងបរិស្ថានក្នុងកំពង់ផែ | ផែនការគ្រប់គ្រងសុខភាព សុវត្ថភាព និងបរិស្ថានកំពង់ផែ |
| ៥ | អន្តរកម្មជាមួយសហគមន៍ | ដើម្បីជួយអភិវឌ្ឍន៍សហគមន៍ | ផ្តល់វិភាគទានដល់សហគមន៍តាមភាពជាក់ស្តែង |
| ៦ | ការការពារសិទ្ធរបស់ម្ចាស់បំណុល | ធានានូវការទូទាត់សាច់ប្រាក់បម្រុងសម្រាប់បំណុលទៅតាមកាលាវសានន្តនីមួយៗ | ទូទាត់បំណុលអោយបានទាន់ពេលវេលា |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | បង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអោយបានរឹងមាំ | បានត្រួតពិនិត្យដោយសវនករផ្ទៃក្នុង |
| ៨ | ផ្សេងៗ | | |

## ខ. ពិពណ៌នាអំពីទំនួលខុសត្រូវសង្គមរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

| ល.រ | អ្នកទទួលប្រយោជន៍ | ទំហំនៃការបរិច្ចាគ | គោលបំណងនៃការបរិច្ចាគ |
|---|---|---|---|
| ១ | រដ្ឋបាលខេត្តព្រះសីហនុ | ៧៣៨.០០០.០០០,០០ រៀល | បរិច្ចាគសម្រាប់ការសាងសង់ អគារបន្ទប់ទឹកសាធារណៈចំនួន ០២ ទីតាំង តាមបណ្ដាឆ្នេរសមុទ្យ ខេត្តព្រះសីហនុ។ |
| ២ | រដ្ឋបាលស្រុកព្រៃនប់ ខេត្តព្រះសីហនុ | ១២៣.៧៥០.០០០,០០ រៀល | បរិច្ចាគសម្រាប់ការជួសជុល ផ្លូវលំក្រាលក្រួសក្រហមក្នុងឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចំនួន ០៣ខ្សែ ប្រវែង ១,៦៥០ ម៉ែត្រ ទទឹង ០៥ ម៉ែត្រ។ |
| ៣ | រដ្ឋបាលស្រុកព្រៃនប់ ខេត្តព្រះសីហនុ | ៣៧៦.១១០.០០០,០០ រៀល | បរិច្ចាគសម្រាប់ការសាងសង់ អគាររដ្ឋបាលចំនួន ០១ខ្នង ទំហំ ១៨៩ ម៉ែត្រក្រឡា មានពីរជាន់ និងចាក់បេតុងទីធ្លា ៦០០ ម៉ែត្រក្រឡា ស្ថិតនៅឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ |
| ៤ | វិទ្យាល័យ ហ៊ុន សែន មិត្តភាព ខេត្តព្រះសីហនុ | ៨៦.១៧០.០០០,០០ រៀល | បរិច្ចាគសម្រាប់ការសាងសង់តារាងបាល់ទាត់ទំហំ ៥០x១០០ ម៉ែត្រ។ |
| ៥ | ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម | ១៤៧.៩៦៩.០០០,០០ រៀល | បរិច្ចាគសម្រាប់ការសាងសង់ អគារសិក្សាចំនួន ០១ខ្នង មាន ០៥បន្ទប់ ទំហំ ៧,២x៥០ ម៉ែត្រ និងយ៉ខាងមុខទំហំ ៥x៤ ម៉ែត្រ មានផ្ទៃក្រឡាសរុប ៣៦០ ម៉ែត្រ និងដំបូលទំហំ ៥០៦ ម៉ែត្រក្រឡា។ |
| ៦ | ក្រុមការងារថ្នាក់ជាតិចុះជួយ ខេត្តព្រះសីហនុ | ៦៣២.១៩៥.៣៦០,០០ រៀល | បរិច្ចាគជូនក្រុមការងារថ្នាក់ជាតិ ចុះជួយខេត្តព្រះសីហនុ ដើម្បីចូលរួមចំណែកកសាងផ្លូវលេខ ៨៣៥ សង្កាត់លេខ៤ ខេត្តព្រះសីហនុ។ |

## ផ្នែកទី៦. ការបង្ហាញព័ត៌មាន និងតម្លាភាព

### ក. ការបង្ហាញអំពីព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ | មូលហេតុ |
|---|---|---|---|
| ១ | ចក្ខុវិស័យ/ បេសកកម្ម/ គោលដៅអាជីវកម្ម | មានបង្ហាញ | |
| ២ | សូចនាករហិរញ្ញវត្ថុ | មានបង្ហាញ | |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មានបង្ហាញ | |
| ៤ | កត្តាហានិភ័យសំខាន់ៗ | គ្មានបង្ហាញ | ក្នុងឆ្នាំ២០២១ នេះ **កសស** មិនបានវិភាគលើកត្តាហានិភ័យសំខាន់ៗទេ |
| ៥ | គោលនយោបាយភាគលាភ | មានបង្ហាញ | |
| ៦ | ជីវប្រវត្តរបស់អភិបាល | មានបង្ហាញ | |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មានបង្ហាញ | |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ | |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ | |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មានបង្ហាញ | |

ក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២១ នេះ **កសស** មិនបានបង្ហាញនូវសូចនាករមិនមែនហិរញ្ញវត្ថុ ប៉ុន្តែបានបង្ហាញតារាងស្ថិតិលម្អិត និងក្រាហ្វិចអំពីប្រតិបត្តិការរបស់ខ្លួន ។

### ខ. ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មាន ដោយរៀបរាប់ពីមធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុក ផ្តល់ព័ត៌មាន

យន្តការនៃការផ្តល់ព័ត៌មាន ត្រូវបានដាក់បង្ហាញតាមរយៈសារអេឡិចត្រូនិច, គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងគេហទំព័ររបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ។

អ្នកទទួលបន្ទុកផ្តល់ព័ត៌មាន លោក **សម សុភាព** និងសហការី។

### គ. ទំនាក់ទំនងជាមួយវិនិយោគិន

១. បង្ហាញពីយន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន៖

- ទំនាក់ទំនងតាមរយៈលេខទូរស័ព្ទដែលមាននៅក្នុងគេហទំព័ររបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងការអញ្ជើញអោយចូលរួមមហាសន្និបាតភាគហ៊ុនិក របស់ **កសស**។

២. ពិពណ៌នាដោយសង្ខេបអំពីទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងរយៈពេល១(មួយ) ឆ្នាំចុងក្រោយ

- ក្នុងឆ្នាំ២០២១ នេះ មានការអញ្ជើញអោយចូលរួមមហាសន្និបាតភាគហ៊ុនិករបស់ **កសស** និងមានជាសំណួរ និងចម្លើយដល់វិនិយោគិនណាដែលមានចម្ងល់មកកាន់ **កសស** ។